ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

**អង្គជំនុំជម្រះតុលាការកំពូល**

Supreme Court Chamber

Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

Case File/Dossier N°. 002/19-09-2007-ECCC/SC

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 26-Feb-2021, 09:25
CMS/CFO: Sann Rada

នៅចំពោះមុខ៖

**ចៅក្រម គង់ ស្រ៊ឹម ប្រធាន**

**ចៅក្រម Chandra Nihal JAYASINGHE**

**ចៅក្រម សោម សិរីវឌ្ឍ**

**ចៅក្រម Florence Ndepele Mwachande MUMBA**

**ចៅក្រម ម៉ុង មុន្នីចរិយា**

**ចៅក្រម Maureen Harding CLARK**

**ចៅក្រម យ៉ា ណារិន**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០២១

ភាសាដើម៖ ខ្មែរ/អង់គ្លេស

ចំណាត់ថ្នាក់ឯកសារ៖ សាធារណៈ

---

# ការអញ្ជើញដាក់សេចក្ដីសង្ខេបលើកាលវិភាគសម្រាប់សវនាការបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២

---

**សហព្រះរាជអាជ្ញា**

ជា លាង

Brenda HOLLIS

**ជនជាប់ចោទ**

ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**

ពេជ អង្គ

Megan HIRST

**សហមេធាវីជនជាប់ចោទ ខៀវ សំផន**

គង់ សំអុន

Anta GUISSÉ

**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រាប់កាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យនៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ (“អង្គជំនុំជម្រះតុលាការកំពូល”)

**កត់សម្គាល់ឃើញ**ថា នៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសសាលក្រម និងប្រកាសទោសក្នុងសំណុំរឿង ០០២/០២ ដោយផ្ទាល់មាត់នូវសេចក្តីសង្ខេបនៃការយល់ឃើញរបស់ខ្លួន និងផ្នែកសម្រេចសេចក្តីនៃសាលក្រម

**កត់សម្គាល់ឃើញ**ថា សាលក្រមជាលាយលក្ខណ៍អក្សរបន្ទាប់មកត្រូវបានជូនដំណឹងដល់ភាគីជាភាសាខ្មែរ បារាំង និងអង់គ្លេស នៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៩ (“អង្គជំនុំជម្រះសាលាដំបូង”)[1]

**ដោយបានទទួល**បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ដែលបានធ្វើឡើងដោយសហព្រះរាជអាជ្ញា[2] និង ខៀវ សំផន[3] និងសារណាតបរបស់ភាគីនីមួយៗ[4]

**រំលឹក**ថា នៅថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០២០ មន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់របស់អង្គជំនុំជម្រះតុលាការកំពូល បានជូនដំណឹងក្រៅផ្លូវការដល់ភាគីពាក់ព័ន្ធតាមរយៈការទំនាក់ទំនងតាមអ៊ីមែលថា អង្គជំនុំជម្រះតុលាការកំពូលកំពុងរៀបចំធ្វើសវនាការបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ នៅសប្តា

[1] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ E465។ ជាផ្នែកនៃបណ្តឹងសាទុក្ខដែលស្ថិតក្រោមការពិចារណា ខៀវ សំផន បានជំទាស់ទៅនឹងភាពស្របច្បាប់នៃដំណើរការនៃការប្រកាសសាលក្រម។

[2] បណ្តឹងសារទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៩ F50។

[3] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (សំណុំរឿង ០០២/០២) ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០២០ F54។

[4] សារណាតបរបស់ ខៀវ សំផន ទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៩ F50/1។ សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០២០ F54/1។ សារណាតបរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០២១ F54/2។

ហ៍ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០២១[5]

**រំលឹក**ថា អនុលោមតាមវិធាន ១០៨(៣) នៃវិធានផ្ទៃក្នុង ក្រឡាបញ្ជីរបស់អង្គជំនុំជម្រះតុលាការកំពូលបានជូនដំណឹងដល់ភាគីពាក់ព័ន្ធទាំងអស់ នៅថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០២១ ថា អង្គជំនុំជម្រះតុលាការកំពូលនឹងធ្វើសវនាការបណ្តឹងសាទុក្ខ ចាប់ពីថ្ងៃទី ១៧ ដល់ ២១ ខែ ឧសភា ឆ្នាំ ២០២១ និងថា ដីកាកំណត់កាលបរិច្ឆេទសវនាការស្តីពីព័ត៌មានជាក់លាក់ នឹងត្រូវចេញក្នុងពេលវេលាសមស្រប[6]

**អាស្រ័យហេតុនេះ**

**ភ្ជាប់**មកជាមួយនូវកាលវិភាគបណ្តោះអាសន្នសម្រាប់សវនាការបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២[7]

**អញ្ជើញ**ភាគីដាក់សេចក្តីអង្កេតរបស់ខ្លួនតាមកាលវិភាគ ប្រសិនបើមាន ក្នុងរយៈពេលពីរសប្តាហ៍គិតចាប់ពីការដាក់សេចក្តីអញ្ជើញនេះ។

**ជូនដំណឹង**ភាគីថា ដីកាកំណត់កាលបរិច្ឆេទសវនាការនឹងត្រូវចេញឆាប់ៗបន្ទាប់ពីមានការសម្រេចលើកាលវិភាគសាធារណៈ និងការកំណត់នូវសំណួរជាក់លាក់ដែលរំពឹងទុកថា សារណាផ្ទាល់មាត់របស់ភាគីនឹងផ្តោតទៅលើនោះ។

**រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០២១**

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ឹម**

[5] អ៊ីមែលរបស់មន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់របស់អង្គជំនុំជម្រះតុលាការកំពូល ចំណងជើង "ឆ្លើយ៖ សវនាការបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ - ប្តូរកាលបរិច្ឆេទ" ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០២០ នៅម៉ោង ០៦ និង ២២ នាទី ព្រឹក ដែលដាក់នៅអង្គជំនុំជម្រះតុលាការកំពូល។

[6] ការជូនដំណឹងអំពីកាលបរិច្ឆេទសវនាការបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ អនុលោមតាមវិធានផ្ទៃក្នុង ១០៨(៣) ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០២១ F58។

[7] ឧបសម្ព័ន្ធ - កាលវិភាគសវនាការ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០២១ ឯកសារលេខ F60។